## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១៦ ខែ មករា ឆ្នាំ២០១៤

# ជប៉ុនផ្តល់ ១១២,៤២៣ ដុល្លារអាមេរិក សម្រាប់គម្រោង តំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន (ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ - ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន១១២,៤២៣ ដុល្លារអាមេរិក ដល់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកែបសម្រាប់គម្រោងតំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងកែបនិងស្រុកដំណាក់ចង្អើរខេត្តកែប។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកយស់ មុន្នី ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកែប នៅស្ថានទូតជប៉ុន។



ទឹកប្រែជាល្អក់ដោយល្បាយពីតក់

មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្តកែប នឹងអនុវត្តគម្រោងតំឡើងប្រព័ន្ធចម្រោះទឹកខ្នាតធំ ដែលអាចច្រោះទឹកបាន ២,០០០ - ២,៥០០លីត្រ ក្នុងមួយម៉ោង ដែលនឹងចែកចាយទៅតាមស្ថានីយ៍ចែកចាយទឹកធំៗ ចំនួនបី ក្នុងក្រុងកែប និងស្រុកដំណាក់ចង្អើរ ហើយប្រព័ន្ធបន្សុតទឹក ក៏នឹងត្រូវតំឡើងក្រោមគម្រោងនេះផងដែរ។ គម្រោងនេះក៏បានផ្តល់ជូននូវ រឺម៉កម៉ូតូចំនួន៣គ្រឿង និង ធុងផ្លាស្ទីកសម្រាប់ដាក់ទឹកចំនួន១២០ធុងដើម្បីដំណើរការប្រព័ន្ធចែកចាយទឹកក្នុងតំបន់គោលដៅផងដែរ។ ជា ផ្នែកមួយក្នុងគម្រោងនេះផងដែរ អ្នក បច្ចេកទេសជប៉ុននឹងផ្តល់ការបណ្តុះបណ្តាលដល់ប្រជាជនក្នុងភូមិអំពីការគ្រប់គ្រងនិងថែទាំឧបករណ៍ចម្រោះទឹកឲ្យបានត្រឹមត្រូវ។ យើងសង្ឃឹមថាប្រជាជនក្នុងភូមិប្រមាណ ៨,៤៩០ នាក់ និងភ្ញៀវទេសចរណ៍ប្រមាណ ៧៦០,០០០ នាក់ ដែលមកកំសាន្តជារៀងរាល់ឆ្នាំអាចទទួលបានទឹកស្អាតមានសុវត្ថិភាពប្រើប្រាស់ពេញមួយឆ្នាំៗ។

ជំនួយ *គូសាណូណិ* របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង ភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការ ចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជា ជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥០.៦ លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួ ន៥០៦ គម្រោង នៅទូទាំង ប្រទេស។




ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០
អ៊ីមែល: eco.jpn@.pp.mofa.go.jp
គេហទំព័រ: http://www.kh.emb-japan.go.jp